# ក្របខ័ណ្ឌការងារ

## មន្ត្រីគម្រោងជាន់ខ្ពស់ផ្នែកទំនាក់ទំនងសហគមន៍

MARIE STOPES CAMBODIA
Children by choice, not chance

មន្ត្រីគម្រោងជាន់ខ្ពស់ផ្នែកទំនាក់ទំនងសហគមន៍ គឺជាអ្នកអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពនានាឱ្យមានប្រសិទ្ធភាព ក្នុងគោលបំណងធ្វើយ៉ាងណាជានាឱ្យបាននូវទំនាក់ទំនងល្អរឹងមាំជាមួយនឹងសហគមន៍ ក៏ដូចជាធ្វើការក្នុងភាពជាដៃគូជាមួយនឹងក្រុមសហគមន៍ និងបុគ្គលផ្សេងៗទៀតក្នុងសហគមន៍ នៅតាមបណ្តាទីកន្លែងនានាដែលមានម៉ារីស្តូបអន្តរជាតិ កម្ពុជាបម្រើការ។ ជាពិសេសទៅទៀត មុខតំណែងការងារនេះ នឹងខិតខំធ្វើយ៉ាងណាបង្កើនអត្រានៃការចូលរួម និងការបញ្ជូន ទាំងក្នុងចំណោមអតិថិជនមានស្រាប់ និងអតិថិជនថ្មី ក្នុងនោះរួមមានទាំងស្ត្រីក្នុងវ័យបន្តពូជ យុវវ័យ ក្មេងជំទង់ និងជនពិការផងដែរ។ ជាមួយនឹងការអនុវត្តយុទ្ធសាស្ត្រនានាដ៏មានប្រសិទ្ធភាព សមិទ្ធផលសំខាន់ដែលមុខតំណែងការងារនេះត្រូវសម្រេចបាន គឺធ្វើឱ្យមានតម្រូវការកើនឡើងចំពោះសេវាទាំងឡាយរបស់យើងតាមគ្រប់បណ្តាញទាំងអស់ (មណ្ឌលម៉ារីស្តូប ម៉ារីស្តូបឡេឌី ការិយាល័យផ្តល់ព័ត៌មាន) នៅក្នុងសហគមន៍នានាដែលមានម៉ារីស្តូបដំណើរការ។ តួនាទីការងារនេះក៏នឹងត្រូវចូលរួមពាក់ព័ន្ធផងដែរជាមួយនឹងមន្ត្រីគម្រោងផ្នែកទំនាក់ទំនងសហគមន៍ដែលមានស្រាប់ និងមន្ត្រីគម្រោងផ្នែកទំនាក់ទំនងសហគមន៍ថ្មីៗផ្សេងទៀត សម្រាប់ការធ្វើអភិបាល ការផ្តល់យោបល់ត្រលប់ និងការតាមដានត្រួតពិនិត្យលើការអនុវត្តសកម្មភាពនានា។

| មុខតំណែងការងារ | ទីកន្លែងធ្វើការ | រាយការណ៍ជូនទៅ | រយៈពេលសាកល្បងការងារ |
|---|---|---|---|
| មន្ត្រីគម្រោងជាន់ខ្ពស់ផ្នែកទំនាក់ទំនងសហគមន៍ | ភ្នំពេញ (ចុះបំពេញបេសកកម្មញឹកញាប់ទៅតាមបណ្តាទីកន្លែងនានាក្រៅរាជធានីភ្នំពេញ) | ប្រធានគ្រប់គ្រងផ្នែកម៉ាឃីធីងរួម | 3 ខែ |

ម៉ារីស្តូបអន្តរជាតិ កម្ពុជា គឺជាអង្គការសាកលមួយដែលផ្តល់សេវាពន្យារកំណើតតាមតម្រូវការ និងសេវារំលូតកូនដោយសុវត្ថិភាពជូនដល់ស្ត្រី និងក្មេងស្រីទាំងឡាយ។ ក្រុមការងាររបស់យើងប្រមូលផ្តុំទៅដោយបុគ្គលិកមានជំនាញវិជ្ជាជីវៈខ្ពស់ និងមានឆន្ទៈមុតមាំក្នុងការបំពេញការងាររបស់ខ្លួនក្នុងសហគមន៍នានានៅទូទាំង 37 ប្រទេស។ រាល់សេវាទាំងឡាយដែលយើងផ្តល់ជូន គឺជួយបង្កលទ្ធភាពឱ្យស្ត្រីជ្រើសរើសពេលវេលាសមស្របណាមួយក្នុងការមានកូន ដើម្បីឱ្យគាត់អាចបន្តផែនការ និងក្តីសុបិនរបស់ខ្លួន និងក្រុមគ្រួសារ។ ម៉ារីស្តូបអន្តរជាតិ កម្ពុជា (ម៉ារីស្តូប) បង្កើតឡើងក្នុងឆ្នាំ 1998 ហើយកំពុងដំណើរការគ្លីនិកសុខភាពបន្តពូជរបស់ខ្លួនចំនួន 7 កន្លែង និងជាបណ្តាញការងារមួយរបស់ម៉ារីស្តូបឡេឌីនៅតាមសហគមន៍ ព្រមទាំងជាអង្គការមួយផ្តល់ការគាំទ្រផ្នែកបច្ចេកទេសជូនដល់ដៃគូនានាដែលជាស្ថាប័នរដ្ឋ និងស្ថាប័នឯកជនជាច្រើនផងដែរ។ ក្នុងឆ្នាំ2018 ម៉ារីស្តូបមានផ្តល់សេវានានាដល់ស្ត្រី និងបុរសសរុបចំនួន 70,000នាក់នៅទូទាំងប្រទេសកម្ពុជា។ ការទទួលខុសត្រូវសំខាន់របស់មុខតំណែងនេះ គឺដើម្បីបន្តសម្រេចតាម**ចក្ខុវិស័យរបស់ម៉ារីស្តូបៈ ពិភពលោកមួយដែលរាល់កំណើតទាំងអស់សុទ្ធតែជាការចង់បាន** និងបេសកកម្មរបស់ម៉ារីស្តូប ដែលធានាដល់បុគ្គលម្នាក់ៗទទួលបានសិទ្ធិៈ **មានកូនតាមប្រាថ្នា មិនមែនតាមការចៃដន្យ**។

# ក្របខ័ណ្ឌការងារ

## មន្ត្រីគម្រោងជាន់ខ្ពស់ផ្នែកទំនាក់ទំនងសហគមន៍

MARIE STOPES CAMBODIA
Children by choice, not chance

បុគ្គលិកដែលកាន់តួនាទីការងារនេះ ត្រូវគោរព លើកស្ទួយ និងអនុវត្តបំពេញចំពោះគុណតម្លៃស្នូលទាំងឡាយរបស់ម៉ារីស្តូប ដែលនេះគឺជាលក្ខខ័ណ្ឌតម្រូវដ៏ចាំបាច់មួយសម្រាប់តួនាទីនេះ។

| អនុវត្តតាមបេសកកម្ម | ផ្តោតសំខាន់លើអតិថិជន | ទទួលខុសត្រូវ | ក្លាហាន |
|---|---|---|---|

| ការទទួលខុសត្រូវសំខាន់ៗ | សូចនាករវាស់វែង |
|---|---|
| **សកម្មភាពទំនាក់ទំនងសហគមន៍** | |
| • ធ្វើការជាមួយក្រុមការងារផ្នែកម៉ាឃីធីងរួម ដើម្បីបង្កើតចេញជាសកម្មភាពសហគមន៍ នានាដែលមានប្រសិទ្ធភាព និងបង្កើតចេញនូវផែនការប្រចាំឆ្នាំមួយសម្រាប់បង្កើនអត្រានៃការចូលរួម ក្នុងចំណោមអតិថិជនគោលដៅទាំងឡាយ តាមរយៈបណ្តាញផ្តល់សេវាទាំងអស់។<br>• អនុវត្ត សម្របសម្រួល និងចូលរួមនៅក្នុងសកម្មភាពសហគមន៍ទាំងឡាយដើម្បីបង្កើនអត្រាតម្រូវការចំពោះមធ្យោបាយពន្យារកំណើត ការរំលូតកូនដោយសុវត្ថិភាព និងសេវាសុខភាពផ្លូវភេទ សុខភាពបន្តពូជផ្សេងៗទៀត។<br>• ដាក់សំណើ និងបំពេញរាល់ទម្រង់បែបបទតម្រូវផ្សេងៗដើម្បីទទួលបានការអនុម័តយល់ព្រមពីអាជ្ញាធរមូលដ្ឋាន សម្រាប់ធ្វើសកម្មភាពការងារក្នុងសហគមន៍។<br>• ចូលរួមពាក់ព័ន្ធ និងសម្របសម្រួលការងារជាមួយអ្នកដឹកនាំសហគមន៍ ប្រធានអង្គភាព សុខាភិបាលមូលដ្ឋាន អ្នកមានឥទ្ធិពលសំខាន់ៗ និងអ្នកតស៊ូមតិសុខភាពផ្លូវភេទ និងសុខភាពបន្តពូជនានា ដើម្បីផ្សព្វផ្សាយលើកកំពស់ដល់សេវាទាំងឡាយរបស់ម៉ារីស្តូប។<br>• ជួយ និងគាំទ្រក្នុងការអនុវត្តការងារបង្កើតតម្រូវការក្នុងមូលដ្ឋាន/សកម្មភាពទីផ្សារនានារបស់មណ្ឌល និងម៉ារីស្តូបឡេឌី។ | • ផែនការប្រចាំឆ្នាំដែលមានរៀបរាប់អំពីសកម្មភាពសហគមន៍នានា បានបង្កើតរួចរាល់សម្រាប់អនុវត្ត។<br>• សកម្មភាពសហគមន៍បានអនុវត្តត្រឹមត្រូវ និងទាន់ពេលវេលា។<br>• ការចូលរួម និងការបញ្ជូនក្នុងចំណោមអតិថិជនគោលដៅមានអត្រាកើនឡើង។<br>• សូចនាករលទ្ធផលការងារ សំខាន់ៗ សម្រាប់សកម្មភាពសហគមន៍សម្រេចបានជោគជ័យ។ |
| **ភាពជាដៃគូ ការបញ្ជូន និងការធ្វើអភិបាល** | |
| • កំណត់ជ្រើសរើស ទាក់ទង និងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីគម្រោងផ្នែកទំនាក់ទំនងសហគមន៍ទាំងឡាយ ដោយរួមទាំងភ្នាក់ងារបញ្ជូន និងអ្នកស្ម័គ្រចិត្តសុខភាពផងដែរ អំពីចំណេះដឹងមូលដ្ឋានទាក់ទិននឹងការពន្យារកំណើត ការរំលូតកូនដោយសុវត្ថិភាព ជំនាញប្រាស្រ័យទាក់ទងអន្តរបុគ្គល និងប្រធានបទផ្សេងៗទៀតដែលពាក់ព័ន្ធ។ | • មន្ត្រីគម្រោងផ្នែកទំនាក់ទំនងសហគមន៍បានកំណត់ជ្រើសរើស ធ្វើអភិបាល និងតាមដានត្រួតពិនិត្យជាប្រចាំ។<br>• អត្រាបញ្ជូនកើនឡើង<br>• កិច្ចព្រមព្រៀងភាពជាដៃគូបានធ្វើរួចរាល់ជាស្ថាពរ |

# ក្របខ័ណ្ឌការងារ

## មន្ត្រីគម្រោងជាន់ខ្ពស់ផ្នែកទំនាក់ទំនងសហគមន៍

MARIE STOPES CAMBODIA
Children by choice, not chance

| ការទទួលខុសត្រូវសំខាន់ៗ | សូចនាករវាស់វែង |
|---|---|
| • ធ្វើអភិបាល ផ្តល់យោបល់ត្រលប់ និងតាមដានត្រួតពិនិត្យលើមន្ត្រីគម្រោងផ្នែកទំនាក់ទំនងសហគមន៍ និងការអនុវត្តសកម្មភាពនានា។ ផ្តល់ការបណ្តុះបណ្តាល និងការបង្ហាត់បង្រៀនបន្ថែម តាមករណីដែលចាំបាច់។<br>• សហការជាដៃគូ ឬចូលរួមពាក់ព័ន្ធនៅក្នុងសកម្មភាពនានាជាមួយអង្គការសហគមន៍ ក្រុម សមាគម ក្លឹប និងអ្នកផ្សេងៗទៀតដែលធ្វើការក្នុងចំណោមអតិថិជនគោលដៅរបស់ម៉ារីស្តូប ដោយត្រូវប្រាស្រ័យទាក់ទងគ្នាជាមួយនឹងក្រុមការងារផ្នែកទីផ្សាររួម ។ | |
| **ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងការធ្វើរបាយការណ៍** | |
| • ធ្វើអង្កេតវាស់ស្ទង់ការផ្តល់យោបល់ត្រលប់ និងបញ្ជូនរបាយការណ៍ក្រោយពេលអនុវត្តសកម្មភាពផ្សេងៗ រួមទាំងរូបថតនានាផងដែរ បន្ទាប់ពីបានធ្វើសកម្មភាពទីផ្សារ/សកម្មភាពផ្សព្វផ្សាយ/សកម្មភាពសហគមន៍រួច ដើម្បីកែលម្អដល់ការអនុវត្តសកម្មភាពនានាក្នុងពេលអនាគតឱ្យបានកាន់តែប្រសើរ។<br>• បង្កើត និងកែលម្អលើជំនួយការងារ (job aids) និងសម្ភារៈផ្សព្វផ្សាយទីផ្សារនានាសម្រាប់ការកៀរគរសហគមន៍។<br>• បំពេញ និងបញ្ជូនរបាយការណ៍សកម្មភាពទីផ្សារ (MAR) ជារៀងរាល់ខែ។ | • របាយការណ៍ក្រោយពេលអនុវត្តសកម្មភាពបានបញ្ជូនទាន់ពេលវេលា<br>• របាយការណ៍សកម្មភាពទីផ្សារ (MAR)បានបញ្ជូនទាល់ពេលវេលា<br>• ជំនួយការងារ និងសម្ភារៈផ្សព្វផ្សាយនានាបានពិនិត្យសារឡើងវិញ និងបានកែសម្រួលរួចក្នុងករណីចាំបាច់ |

## ជំនាញ និងបទពិសោធន៍

### គុណវុឌ្ឍិ

- មានបទពិសោធន៍ការងារល្អពាក់ព័ន្ធនឹងទំនាក់ទំនងសហគមន៍ប្រកបដោយប្រសិទ្ធភាព និងការបង្កើតភាពជាដៃគូ
- បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឬមានបទពិសោធន៍ជាមួយការសិក្សានៅមហាវិទ្យាល័យកាន់តែប្រសើរ ប៉ុន្តែមិនជាប្រការតម្រូវនោះទេ

### បទពិសោធន៍ការងារ

- មានបទពិសោធន៍ធ្វើការងារដែលពាក់ព័ន្ធ យ៉ាងហោចណាស់ពីរឆ្នាំ
- មានបទពិសោធន៍ធ្វើការជាមួយក្រុមសហគមន៍ ឬក្រុមបុគ្គល ទាំងនៅក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាល
- មានបទពិសោធន៍អនុវត្តការងារ និងសម្របសម្រួលការងារនៅក្នុងសហគមន៍ដើម្បីលើកកំពស់ការយល់ដឹង ឬអប់រំផ្សព្វផ្សាយអំពីសេវា/ផលិតផលនានា

# ក្របខ័ណ្ឌការងារ

## មន្ត្រីគម្រោងជាន់ខ្ពស់ផ្នែកទំនាក់ទំនងសហគមន៍

MARIE STOPES CAMBODIA
Children by choice, not chance

| ការទទួលខុសត្រូវសំខាន់ៗ | សូចនាករវាស់វែង |
|---|---|
| • មានបទពិសោធន៍ធ្វើការផ្សព្វផ្សាយសារអប់រំសំខាន់ៗក្នុងចំណោមអតិថិជនសក្តានុពល និងក្រុមអ្នកពាក់ព័ន្ធនានា<br>• មានបទពិសោធន៍ក្នុងការគ្រប់គ្រង ឬផ្តល់ការបណ្តុះបណ្តាលទៅដល់បុគ្គលិកស្ម័គ្រចិត្ត និងបុគ្គលិកក្រុមការងារ | |

| ជំនាញ | ឥរិយាបថ/ការលើកទឹកចិត្ត |
|---|---|
| • មានជំនាញក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព តាមរយៈការស្តាប់ដោយសកម្ម និងជំនាញក្នុងការសាកសួរសំណួរ ដោយប្រើប្រាស់ភាសាកាយវិការ និងជានាថាព័ត៌មានដែលបានផ្តល់មានភាពច្បាស់លាស់ និងជាក់លាក់ត្រឹមត្រូវ។<br>• ជាអ្នកគិតប្រកបដោយយុទ្ធសាស្ត្រ ដែលអាចវិភាគមើលដឹងពីកត្តាឱកាស និងកត្តាគំរាមកំហែងនានា ដើម្បីអាចបង្កើតទំនាក់ទំនងដោយជោគជ័យជាមួយនឹងអតិថិជនសក្តានុពល/ដៃគូនៅក្នុងសហគមន៍របស់យើង។<br>• មានភាពច្នៃប្រឌិតខ្ពស់ក្នុងការជម្រុញបំផុសគំនិត និងចេះស្វែងរកទំនាក់ទំនងសក្តានុពលរវាងសកម្មភាពសហគមន៍ និងការងាររបស់ម៉ារីស្តូប។<br>• មានភាពចុះសម្រុងល្អ និងមានទំនុកចិត្តខ្ពស់ក្នុងការប្រាស្រ័យទាក់ទងគ្នាជាមួយស្ថាប័នរដ្ឋ និងអាជ្ញាធរមូលដ្ឋាននានា។<br>• មានទំនុកចិត្តខ្ពស់ក្នុងការសម្របសម្រួលកិច្ចពិភាក្សាស្តីពីការរំលូតកូនដោយសុវត្ថិភាព និងប្រធានបទរសើបនានាក្នុងចំណោមក្រុមស្ត្រី និងបុរស រួមទាំងយុវវ័យ និងជនពិការផងដែរ។ | • ជាអ្នកគាំទ្រទាំងស្រុងទៅលើការលើកកំពស់សិទ្ធិស្តីពីសុខភាពផ្លូវភេទ និងសុខភាពបន្តពូជសម្រាប់ស្ត្រី និងបុរសគ្រប់រូប រួមទាំងសេវារំលូតកូនដោយសុវត្ថិភាពផងដែរ។<br>• ជាអ្នកផ្តោតសំខាន់លើលទ្ធផល - សម្រេចការងារលើសពីការរំពឹងទុក<br>• ជាអ្នកចេះលើកទឹកចិត្តដល់ខ្លួនឯង/ជាអ្នកចេះចាប់ផ្តើមដោយខ្លួនឯង<br>• ជាអ្នកចេះធ្វើការដឹកនាំក្រុម<br>• ជាអ្នកជម្រុញ និងមានកិច្ចប្តេជ្ញាខ្ពស់ក្នុងការសម្រេចលទ្ធផលឱ្យបានជោគជ័យ<br>• ជាអ្នកចេះគិតគូរត្រៀមជាមុន និងចេះចាត់វិធានការសមស្របដើម្បីប្រើប្រាស់ឱកាសនានាយ៉ាងមានប្រយោជន៍បំផុត តាមរយៈការរិះរកនូវមធ្យោបាយដោះស្រាយនានាប្រកបដោយប្រសិទ្ធភាព។ |